**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៣ . សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- បានឃើញសេចក្តីសម្រេចលេខ ០៣ សសរ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួល និងបំពេញបន្ថែមសមាសភាពគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ដូចខាងក្រោម៖

១-ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាអនុប្រធាន

២-ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ជាអនុប្រធាន
ជំនួសឯកឧត្តម **កែប ជុតិមា**

៣-ឯកឧត្តម **ផៃ ម៉ិនឈឿន** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ជាសមាជិក
ជំនួសឯកឧត្តម **ឈុន ស៊ីរុន**

៤-ឯកឧត្តម **ទៀម សុគន្ធ** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា ជាសមាជិក

៥-ឯកឧត្តម **មាន សុតា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិក

៦-ឯកឧត្តម **សុំហោង បុរស** អគ្គនាយកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុនៃ
ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ជាសមាជិក

៧-ឯកឧត្តម **គីម ហុង** អគ្គនាយកបច្ចេកទេសនៃក្រសួងសង្គមកិច្ច
អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក

៨-ឯកឧត្តម **ឡូច ចាន់នី** អគ្គាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា ជាសមាជិក

៩-លោក **ម៉ក់ ឧសភា** ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
នៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

**ប្រការ ២.-**

ត្រូវបានបំពេញបន្ថែមសមាសភាពអគ្គលេខាធិការដ្ឋាន នៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ដូចខាងក្រោមៈ

១-ឯកឧត្តម **ម៉ៅ ច័ន្ទតារា** អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃ
ក្រសួងមហាផ្ទៃ
ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ក.ប.

២-ឯកឧត្តម **ស៊ិន សុផានី** មេបញ្ជាការរង និងជាស្នងការ នៃស្នងការដ្ឋានស្រាវជ្រាវ
យុត្តិធម៌នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគ.ក.ប.

៣-ឯកឧត្តម **គៀត ច័ន្ទថារិទ្ធ** ប្រធានសេនាធិការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ
នៃក្រសួងមហាផ្ទៃ
ជាសមាជិកនៃអគ្គលេខាធិការដ្ឋានគ.ក.ប.

៤-ឯកឧត្តម **ហុង ពិណុល** ស្នងការនៃស្នងការដ្ឋានព័ត៌មានសន្តិសុខ
នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
ជាសមាជិកនៃអគ្គលេខាធិការដ្ឋានគ.ក.ប.

៥-ឯកឧត្តម **សេង សក្ដា** អគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ជាសមាជិកនៃអគ្គលេខាធិការដ្ឋានគ.ក.ប.

៦-លោក **អ៊ិន ខេមរា** ប្រធាននាយកដ្ឋានអធិការកិច្ចនៃក្រសួងការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ជាសមាជិកនៃអគ្គលេខាធិការដ្ឋានគ.ក.ប.

៧-លោក **កុយ ទេពដារ៉ាឧត្តម** ប្រធាននាយកដ្ឋានវិវាទការងារក្រសួងការងារនិង
បណ្តុះបណ្តាលវិជ្ជាជីវៈ

ជាសមាជិកនៃអគ្គលេខាធិការដ្ឋានគ.ក.ប.

៨-លោក **អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ជាសមាជិកនៃអគ្គលេខាធិការដ្ឋានគ.ក.ប.

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួនដែលមាន ចែងក្នុងប្រការ ១ និងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១៣
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ១ ប្រការ ២
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ